ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚ ❖ ៛

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ៦២០ អយក.ប្រក

# ប្រកាស

## ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ ទួលសាលា មកជាសាលាបឋមសិក្សាពេញលក្ខណៈ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

-បានពិនិត្យលិខិតលេខ ១០១ សព.អប ចុះថ្ងៃទី ៣០ ខែ ៣ ឆ្នាំ ២០០១ របស់នាយកសាលាបឋមសិក្សា សម្តេចក្រុមព្រះ នរោត្តមរណឫទ្ធិ ឃុំ អន្លង់រមៀត ដែលមានចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កណ្តាល

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សម្រេច

**ប្រការ១:**- ផ្តាច់សាលាឧបសម្ព័ន្ធ **ទួលសាលា** ពីសាលាបឋមសិក្សា **សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ** ដែលមានទីតាំងស្ថិតនៅ ឃុំ **អន្លង់រមៀត** ស្រុក **កណ្តាលស្ទឹង** **ខេត្តកណ្តាល** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២:**- សាលាបឋមសិក្សា **ទួលសាលា** ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ៣:**- នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤:**- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:**- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡាខេត្ត **កណ្តាល** ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក **កណ្តាលស្ទឹង** នាយកសាលាបឋមសិក្សា **សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ** មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ ,ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០២

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម សេទ្ធី**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាលាខេត្តកណ្តាល

" ដើម្បីជូនជ្រាបជាពតិមាន "

- ដូចប្រការ ៥
- កាលប្បវត្តិ- ឯកសារ នា -ប.ម